# កិច្ចសម្ភាសរបស់លោកតាឈ្មោះ នាង យុន

កៈ អ្នកសម្ភាសឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសម្ភាសឈ្មោះ នាង យុន

កៈ ចាសជាដំបូងសូមជំរាបសួរលោកតា! ចាស ជំរាបសួរលោកតា!

ខៈ មានការអីចៅ!

កៈ ចាស! ថ្ងៃនេះចៅមានឳកាលដើម្បីមកសម្ភាសលោកតាផ្ទាល់ហើយអឺ..ចៅធ្វើការស្ម័គ្រចិត្តនៅក្នុងគំរោងរបស់សាលា BYU ហាវៃនៅខាងសហរដ្ឋអាមេរិចហើយខាងសាលាគឺគេតំរូវអោយចៅសម្ភាសប្រជាជនកម្ពុជាដែលមានវ័យចាប់ពី៣៥ឆ្នាំឡើងអំពីជីវប្រវត្តិពង្សប្រវត្តិរបស់គាត់អញ្ចឹង!

ខៈ អឹម...

កៈ ចាស! តើគាត់មានជីវិតក្នុងការតស៊ូខ្លះរបស់គាត់ដើម្បីទុកអោយកូនចៅជំនាន់ក្រោយគេបានស្តាប់តើលោកតាមានឈ្មោះអីដែរ?

ខៈ ទេ! អារឿងនិងវាអញ្ចេះទេតាវាមានការខ្វះខាតសុំបច្ច័យសិនតែថាអោយបច្ច័យនិយាយឥឡូវនិង(សើច)!

កៈ អូ! ការពិតគំរោងរបស់ខាងសាលាគេអត់មានអោយលុយទេណាលោកតា!

ខៈ គេអត់មានអោយលុយទេអី?

កៈ ចាស!

ខៈ អ៎...អានេះវាជាការធម្មតាទេចៅអើយសង្គ្រាមប្រជាជនតាំងពីទស្សវត្តន៍ឆ្នាំ១៩៧០មកវាមានការខ្វះខាតវាហើយប្រជាជនត្រូវប៉ុលពតវាកាប់សំលាប់បងប្អូនពលករកម្មករនិងរាប់មិនឈ្នះទេនៅតាមជនបទស្រុកស្រែចំការក៏ដូចជាទីក្រុងអញ្ចឹង!

កៈ ចាស! ចុះលោកតា...

ខៈ ប៉ុន្តែធ្វើការធ្វើអីនិងវាគ្រាន់តែថាមានការឆ្លងកាត់ប្រើអោយជីកដីគេប្រើអោយធ្វើជីអាចម៍គេប្រើ

អោយធ្វើទៅតាមមិនដឹងស្អីៗទេគេប្រើសព្វគ្រប់ទាំងអស់ហើយមិនមានការទំនាស់ទាស់ទែងអីទៀតទេល្អទាំងអស់ខាំមាត់សង្កត់ចិត្តនិងដូចថាមានធមិខាន់តីអីនិងបាននៅរស់ហើយបើថាអេ...គេប្រើអោយធ្វើនេះប្រកែកធ្វើនោះប្រកែកទំនាស់ស៊ីបាយមិនឆ្អែតក៏ទំនាស់ស៊ីបាយៗណាស់បបរទឹកៗមួយវែកម្នាក់និងហាស់ថាហូបមិនឆ្អែតនិងក៏អត់បានដែរ!

កៈ អឺម...ចាស

ខៈ ទាល់តែមានធមិខាន់តីអត់ធ្មត់សាច់ឈាមអីមិនថ្លាអញ្ចឹងទេឆ្អឹងនិងហើយគេប្រើអោយធ្វើការនិងមើលម៉ោងពីរៗឡើងពីម៉ោងបួន ម៉ោងបួនសំរាកប្រុងអីនិងទៅម៉ោងបួនកន្លះចេញទៅកាប់ដីដល់ម៉ោងពីរដណ្ដប់ (ម៉ោង១២) បានសំរាកៗមកហូបបាយហូបអីម៉ោងមួយម៉ោងអីនិងបានចុះទៅធ្វើការទៀត ហើយគ្មានម្លប់ជ្រកទេក្ដៅរហូតនិងវេទនាណាស់!

កៈ ចាស!

ខៈ ទៅលើការឆ្លងកាត់ជីវិតហើយបងប្អូននោះមានប្រាំពីរនាក់!

កៈ អឺម...

ខៈ ស្លាប់អស់បួននាក់ហើយគេសម្លាប់!

កៈ បងប្អូនរបស់លោកតាមានឈ្មោះអីខ្លះដែរ?

ខៈ បាទ!

កៈ បងប្អូនរបស់លោកតាគាត់មានឈ្មោះអ្វីខ្លះដែរ?

ខៈ ឈ្មោះបងទីមួយគាត់មានឈ្មោះ ណាម ឈ្មោះ គង់ហើយអឺ...បងម៉ាយ ឈ្មោះ ស៊ុម!

កៈ ចាស! មានបួននាក់ ស្រីប៉ុន្មាននាក់ប្រុសប៉ុន្មាននាក់ដែរលោកតា?

ខៈ ស្លាប់បាត់អស់ហើយរកមិនឃើញផងកាលពីស្វែងរកចេះតែស្វែងរកទៅបើថាចេះតែរកអីបើគេបញ្ជូនទៅស្រុកលិចអស់ហើយ!

កៈ អឺម!

ខៈ តំបន់និងគេហៅថាតំបន់លិចណាស់!

កៈ ចាស!

ខៈ មិនដឹងនាំទៅណាវាតំបន់លិចឥឡូវខ្ញុំបានអញ្ចេះទេខ្ញុំបាន!

កៈ ហើយលោកតាទាំងលោកតានិងទាំងបងប្អូនទាំងអស់បូននាក់!

ខៈ អឹម!

កៈ ហើយលោកតាមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំៗឈ្មោះ ស៊យ វណ្ណា!

កៈ ឈ្មោះលោកតាត្រូវជាមួយអត្តសញ្ញាណប័ណ្ណអត់លោកតា?

ខៈ បាទ!

កៈ ឈ្មោះរបស់លោកតាត្រូវជាមួយអត្តសញ្ញាណប័ណ្ណឬអត់?

ខៈ ក្នុងអត្តសញ្ញាណប័ណ្ណមានឈ្មោះ នាង យុន ឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណ!

កៈ លោកតា នាង យុន!

ខៈ និងហើយ នាង និងឈ្មោះតានិងណាស់និងហើយ!

កៈ ហើយអឺ...ឈ្មោះនិងអ្នកណាជាអ្នកដាក់អោយលោកតាដែរ?

ខៈ បាទ?

កៈ អ្នកណាគេដែលបានដាក់ឈ្មោះនិងអោយលោកតាដែរ?

ខៈ ដាក់និងគឺម្ដាយឪពុកជាអ្នកដាក់អោយ!

កៈ គាត់ថាមានអត្ថន័យយ៉ាងម៉េចទេសំរាប់លោកតាឈ្មោះ?

ខៈ អឹម...គ្មានអីទេចៅអើយប៉ុន្តែដូចថាតាធ្លាប់ឆ្លងកាត់មកមួយនិងវាពិបាកណាស់!

កៈ ចាស!

ខៈ បើយើងនិយាយពីប្រវត្តិជីវិតក្នុងការរស់នៅនោះ!

កៈ ត្រូវហើយលោកតាមានអាយុវច្រើនហើយឆ្លងកាត់កាត់រឿងច្រើន!

ខ៖ បាទ! ខ្ញុំអាយុចិតសិប ចិតសិបប្រាំឆ្នាំហើយ (៧៥ឆ្នាំ) ជំនាន់ឥស្សរៈនឹងក៏ទាន់អាជំនាន់រដ្ឋកម្ពុជាក៏តែទាន់មកដល់ជំនាន់រាស្ត្រនិយមក៏ទាន់ហើយមកបច្ចុប្បន្នឥឡូវនេះទៀតក៏នៅតែទាន់ដែល!

ក៖ និងហើយ! អញ្ចឹងលោកតាទាន់ជំនាន់ច្រើនណាស់ឥឡូវនិងឯលោកតាមានអាយុប៉ុន្មានហើយ?

ខ៖ តាមានអាយុចិតសិបប្រាំឆ្នាំ (៧៥ឆ្នាំ) ហើយ!

ក៖ អូ!

ខ៖ សើច)!

ក៖ ហើយលោកតាកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ បាទ!

ក៖ លោកតាកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ អូ! តាកើតនៅឆ្នាំមួយពាន់ប្រាំបួនរយសែសិប(ឆ្នាំ១៩៤០) សែសិបប្រាំ សែសិបបីហ៎តែប៉ុននឹងឆ្នាំមួយពាន់ប្រាំបួនរយសែសិបបី (ឆ្នាំ១៩៤៣)!

ក៖ ហើយ...

ខ៖ មិនបានយកអត្តសញ្ញាណប័ណ្ណមកទេ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ហើយលោកតាថ្ងៃខែឆ្នាំវិញលោកតាមានចាំទេ?

ខ៖ អឺម?

ក៖ លោកតាកើតនៅថ្ងៃខែឆ្នាំណាដែរ?

ខ៖ មិនចាំទេភ្លេចបាត់អស់ហើយថ្ងៃខែប៉ុន្តែបើដឹងៗតែកើតឆ្នាំច!

ក៖ កើតឆ្នាំចណ៎លោកតាណ៎!

ខ៖ អើ..

ក៖ ចាស ហើយលោកតាមានកូនចៅទេលោកតា?

ខ៖ ថីមិនមាន ខ្ញុំមាន!

ក៖ កូនចៅរបស់លោកតាពួកគាត់មានអាយុប៉ុន្មានហើយ?

ខ៖
កូនចៅខ្ញុំអាយុអ្នកខ្លះមានអាយុសាមសិបឆ្នាំសែសិបឆ្នាំអីអស់ហើយគេមានប្ដីប្រពន្ធអីរៀបការរួចអស់ហើយ!

ក៖ អឹម!

ខ៖
ប៉ុន្តែតាដល់វាចាស់អញ្ចឹងទៅតាសុំលុយគេនាយអាយនិងគ្រាន់ធ្វើបុណ្យធ្វើទានអីតិចតួចគ្រាន់និងជីវិតរស់នៅនិង

ក៖ ចាស ហើយអញ្ចឹងសព្វថ្ងៃលោកតាមានកូនចៅប៉ុន្មាននាក់មានកូនប៉ុន្មាននាក់ហើយលោកតា?

ខ៖ សព្វថ្ងៃនៅជាមួយកូនពីរនាក់នៅជាមួយកូនពីរនាក់!

ក៖
កូនលោកតាបួននាក់សព្វថ្ងៃលោកតានៅជាមួយកូនពីរនាក់ទេដែលនៅជាមួយលោកតានិង?

ខ៖ បាទ! នៅជាមួយកូនតែពីនាក់និងទេ! សព្វថ្ងៃគេបែករកស៊ីអស់ហើយណាស់!

ក៖ ចាស! ហើយកូនរបស់លោកតាគាត់មានដែរមកលេងលោកតាទេ?

ខ៖ អ្ហាស?

ក៖ កូនដែលបែកទៅនិងគេមានដែលមកលេងលោកតាឫអត់?

ខ៖ គេថីមិនមកលេងប៉ុន្តែគ្នាវាក្រដែរខ្វះខាតអ្នកស្រែចៅដឹងហើយ!

ក៖ ចាស!

ខ៖ វាមិនសូវសំបូរលុយកាក់អីអញ្ចឹងណាស់ខែបុណ្យទានអីនិងគេយកនំចំណីលុយកាក់អីមកជូនខ្ញុំអញ្ចឹងរៀងរាល់ថ្ងៃ
រៀងរាល់ខែរាល់ថ្ងៃដែលនិងប៉ុន្តែវាក៏មានការខ្វះខាត
ហើយលុយកាក់ឥឡូវដូចយើងដឹងស្រាប់ហើយអោយជូនប្រាំពាន់រៀលមួយម៉ឺនរៀលអីនិងមា

នអីចាយតែមួយភ្លែតៗនិងអស់ហើយ ទំនិញនៅស្រុកស្រែថ្លៃដូចទំនិញនៅទីផ្សារអញ្ចឹង សាច់ជ្រូកមួយគីឡូពីរម៉ឺនរៀល មួយគីឡូមួយម៉ឺនប្រាំពាន់រៀលអីអញ្ចឹងណាស់ ដូចតែគ្នានិង!

ក៖ អឹម…ហើយកូនរបស់លោកតាគាត់មានឈ្មោះអ្វីដែរលោកតា?

ខ៖ បាទ!

ក៖ កូនរបស់លោកតាទាំងបួននាក់និងពួកគាត់មានឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះអឺ..ឈ្មោះ ម៉ន ឈ្មោះ ម៉ន ឈ្មោះ គង់ ឈ្មោះ សឹម ឈ្មោះ ភាន អឹម…ប្រុសពីរស្រីពីរណាស់!

ក៖ ហើយចុះលោកយាយត្រូវជាប្រពន្ធរបស់លោកតាគាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះ យ៉ុត!

ក៖ ហើយលោកយាយនិងលោកតារៀបការនៅជាមួយគ្នាប៉ុន្មានឆ្នាំហើយ រៀបការបានប៉ុន្មានឆ្នាំហើយ?

ខ៖ អូ! កាលនិងខ្ញុំរៀបការអាយុច្រើនណាស់ហើយថៅរៀបការតាំងពីអាយុម្ភៃឆ្នាំ (២០ឆ្នាំ) ឥឡូវតាអាយុចិតសិបឆ្នាំ (សំលេងរំខាន)!

ក៖ ចិតសិបប្រាំឆ្នាំហើយ (សើច)!

ខ៖ ចិតសិបឆ្នាំជាងហើយ (សើច)!

ក៖ ចាស! ហើយលោកតាកាលនិងលោកតារៀបការស្រលាញ់គ្នាឬឪពុកម្តាយជាអ្នករៀបចំទុកដាក់អោយ?

ខ៖ អឺ…ខ្ញុំរកនិងរកម្តាយឪពុកជាអ្នករកអោយទេ (សើច) នៅពីដើមនិងខ្ញុំនៅពីរនិងដើមដូចថាយកចិត្តទុកដាក់និងម្តាយឪពុកណាស់ម្តាយឪពុករកអោយដូចថាប្រពន្ធម្តាយឪពុករកអោយច្រើនតែល្អបុរាណនិយាយអញ្ចឹងណាស់!

ក៖ ចាស!

ខ៖
ហើយខ្ញុំក៏មិនជាអ្នកមិនមាត់មិនកអីដែរធម្មតាម៉ែឪគាត់ស្រលាញត្រង់ណាអីត្រង់ណាតាមគាត់អញ្ជឹងទៅណាស់!

ក៖ អឺម!

ខ៖ ប៉ុន្តែកាលនិងគេយកថ្លៃបង្កាប់ពីរពាន់និង ប៉ុន្តែពីពាន់កាលនិងមាសមួយជីតែបីរយនិង!

ក៖ អូ!

ខ៖ មួយជីបីរយ!

ក៖ អញ្ជឹងលោកតានៅខេត្តណាដែរលោកតា?

ខ៖ បាទ!

ក៖ លោកតានៅខេត្តណាដែរ?

ខ៖ ខ្ញុំនៅពីដើមមកខ្ញុំនៅខេត្តព្រៃវែងដល់ពេលខ្ញុំមានគ្រួសារមកនៅស្វាយរៀង!

ក៖ អញ្ជឹងៗ លោកយាយនៅខេត្តស្វាយរៀងហើយលោកតានៅខេត្តព្រៃវែង!

ខ៖ អឺ...និងហើយ!

ក៖ ចុះសព្វថ្ងៃលោកតាមានទីលំនៅ នៅឯណាដែរ?

ខ៖ ខ្ញុំនៅៗព្រៃវែង!

ក៖ អូ! ហើយចុះមិចបានលោកតាមកដល់ភ្នំពេញ?

ខ៖
ដូចថាវាមានការខ្វះខាតច្រើនអញ្ជឹងទៅក៏មករកនៅតាមទីក្រុងអញ្ជឹងទៅមកអញ្ជឹងទៅនៅទីក្រុងគេវាសំបូរលុយកាក់អីនាយអាយគ្រាន់បើជាងស្រុកស្រែនៅស្រុកស្រែរាំងរីងស្ងួតអស់និងលុយកាក់យ៉ាប់ណាស់ មិនសូវសំបូរទេ!

ក៖ អឺម!

ខ៖
ហើយបើមកនៅទីក្រុងអញ្ជឹងគេរកស៊ីគេលក់ដូរអីនាយអាយអញ្ជឹងទៅលុយកាក់គេវារាងធូរជា

រយើងមករកអញ្ចឹងទៅគ្រាន់និងបានធ្វើបុណ្យធ្វើទានហូបចុកអីនាយអោយនិងធម្មតានិងចៅស្រីណាស់!

កៈ ចាស! ហើយលោកតាធ្វើបុណ្យធ្វើទានរយះពេលដែលមានបុណ្យទានបានលោកតាទៅវត្តហ៎?

ខៈ ថ្ងៃប្រាំបីថ្ងៃសីលអីនិងខែដាច់ពេញបោអីនិងខែដាច់អីនិងទៅៗរក្សារសីលតាឈប់ពីព្រោះអឺ...ឈប់ហើយអារឿងកាប់សំលាប់សត្វអីគេនិង!

កៈ ចុះសព្វថ្ងៃលោកតាកាន់សីលប៉ុន្មានដែរ?

ខៈ តាៗកាន់តែសីលប្រាំទេ សីលប្រាំបីក៏តាចេះដែរអឹម...សីលដប់ក៏តាចេះដែរប៉ុន្តែតាមិនអនុវត្តន៍ទៅដល់និងទេតាធ្វើទៅតាមសិក្ខាបទប្រាំបានហើយ អតនាទាន កាមេ សុមធ្វា ចរា តែប៉ុននឹង!

កៈ អឹម!

ខៈ អោយតែវាជាប់សិក្ខាបទប្រាំនិងបានហើយចៅ!

កៈ ត្រូវហើយលោកតា!

ខៈ ហើយបើយើងកាន់ដល់សិក្ខាបទទាំបីលុះត្រាតែយើងនិងថ្ងៃណពេញបោ ថ្ងៃសីលអីនិងយើងអត់ហូបបាយល្ងាច
អ្នកកាន់សីលដប់ប្រៀបបីដូចជាលោកសង្ឃអញ្ចឹងដែលណាស់!

កៈ អឹម!

ខៈ (សើច) ហើយតាមិនបាច់ដល់ប៉ុននឹងទេគ្រាន់តែតាកាន់នូវសិក្ខាបទប្រាំនិងបានហើយ!

កៈ ត្រូវហើយលោកតា!

ខៈ
ប៉ុន្តែអ្វីដែលសំខាន់បំផុតនោះគឺយើងធ្វើមិចដូចថាវៀរចាកនូវអំពើទុច្ចរឹតអំពើអាក្រក់អំពើដែលមានការកាប់សំលាប់គេងប្រវ័ញ្ញលុយកាក់ប្លន់គេសំលាប់គេលួចលុយនាក់ដទៃមិនមើលងាយនិងមិនបៀតបៀនទ្រព្យសម្បិត្តរបស់អ្នកដទៃមិនមើលងាយគេមិនថាក្មេងមិនថាចាស់យើងចេះអត់ធ្មត់អំណត់ណាស់យើងអត់ខាន់ន្តីណាស់
គេថាអោយល្មមសុខចិត្តដើរចេញខ្ញុំមិនសួរតបតមិនសួរអីទេ

ជូនកាលអីនិងដើរមកអញ្ចឹងទៅក្មេងវានៅខ្លាចអញ្ចឹងទៅវាឃើញយើងដើរអញ្ចឹងទៅវាមិនសូវឆ្វេឆ្វាត់(វត់វញ្ញៀវញ្ញៀ)ប៉ុន្មានទេប៉ុន្តែបើយើងគេវាមិនដឹងវាមិនយល់យើងដើរចេញទៅវាជាការល្អ (សំលេងរំខាន)!

ក៖ អឺម..ចាស លោកតា!

ខ៖ ហើយតាមកនេះគ្មានអីទេគ្រន់តែថារកបច្ច័យរកអីនិងសំរាប់ចាយវាយចិញ្ចឹមគ្រួសារគ្រាន់និងជីវិតរស់នៅធ្វើបុណ្យធ្វើទានអីនិងតែប៉ុណ្ណឹង!

ក៖ ចាស! ជីវិតរបស់លោកតាកាលពីពេលមុនដូចជាជំនាន់ប៉ុលពតគេជំលៀសលោកតានិងក្រុមគ្រួសាររបស់លោកតានឹងទៅណាដែរ?

ខ៖ បងប្អូនរបស់ខ្ញុំនឹងត្រូវគេជំលៀសទៅលិចទៅតំបន់ខាងលិចប៉ុន្តែវាមិនដឹងទៅដល់ស្រុកឯណាខ្លះទេហើយគ្មានមកវិញទេទៅនោះ ហើយខ្ញុំនិងគេនិងគេរើសអោយធ្វើជីអាចម៍ណាស់!

ក៖ គេជំលៀសនៅភ្នំពេញនិងមែនលោកតា?

ខ៖ អត់ទេចៅគេជំលៀសទៅនៅឯស្រុក!

ក៖ ចាសលោកតា! លោកតានៅស្រុកណាដែលលោកតា?

ខ៖ នៅខាងស្រុកនៅភូមិគរស្រុកកំសាន្ត!

ក៖ អំ...កាលនិងគេមានធ្លាប់ធ្វើបាបលោកតាទេ?

ខ៖ អត់ទេគេមិនធ្វើបានទេពីព្រោះខ្ញុំមិនដឹងខ្ញុំមិនដឹងយ៉ាងម៉េចពីព្រោះខ្ញុំមិនមាត់មិនកអីទេបើគេប្រើអោយទៅកើតខ្ញុំទៅខាងកើតអញ្ចឹងទៅបើគេប្រើអោយទៅលិចខ្ញុំទៅខាងលិចអញ្ចឹងទៅ
បាយហូបមិនឆ្អែតដឹងតែមិនឆ្អែតហើយប៉ុន្តែអត់មាត់នៅតែថាគេអោយហូបមិនឆ្អែតហើយតិចថា អេ! បាយនិងស៊ីមិនឆ្អែតអីនិងក៏ងាប់ដែរពេលនិងនោះ!

ក៖ លោកតាមានធ្លាប់ឃើញគេយកមនុស្សទៅសំលាប់ចោលទេក្នុងជំនាន់នោះ?

ខ៖ ចឹក៏មិនឃើញ! គេចងទាំងខ្សែរៗឯណោះកូនក្មេងផងខ្ញុំអាណិតៗកូនក្មេងតូចៗគ្នាមិនទាន់នឹងដឹងអីទេគេយកទៅវាយម្តាយឪពុកចោលអស់អញ្ចឹងទៅគេវាយក្មេងៗនិងសំលាប់ពីក្រោយដាក់ព្រនង់និងអញ្ចឹងទៅអ្នកណាៗក៏កំសត់ដូចតែគ្នានឹងដែរ ដល់ពេលឃើញអញ្ចឹងទៅអូយ...មិនកើតទេយកមកពិចារណាឃើញសព្វគ្រប់អញ្ចឹងទៅចៅអើយ មួយជំនាន់មិនដឹងខាងណាអីខាងណីទេបើឃើញអញ្ចឹងហើយកុំថាអេ...នៅក្នុងប្រវត្តិសាស្រ្តគេសំរាប់ក៏សាងរូបក៏សាងមនុស្សគ្មានដែលអ្នកណាយកមនុស្សទៅវាយចោលមែននិងក្នុងជំនាន់ប៉ុលពតសំលាប់មនុស្សចោលគ្មានប្រណីដល់មនុស្សដូចគ្នាអីនោះទេ សំលាប់មនុស្សចោលដូចសំលាប់សត្វធាតុអីអញ្ចឹងដែលមិនស្មើរផង!

ក៖ អឺម!

ខ៖ សំលាប់ចោលខុសត្រូវគ្នាមួយម៉ាត់ពីម៉ាត់ហើយតុលាការសំរេចគ្មានទេអនុម័ត្តគ្នាវាតែម្នាក់ពីនាក់បណ្តោយកែងស្រែទេ បើថាអោយសំលាប់អ្នកណាសំលាប់អ្នកនិងហើយមិនជាអ្នកចេះទេមនុស្សល្ងង់ៗមនុស្សនិងបើនិយាយអោយដូចសម័យឥឡូវនឹងវាថាមនុស្សល្ងិតល្ងង់និងណាស់គេមិនសូវយកមនុស្សចេះមកអោយមកធ្វើការងារនោះទេ មនុស្សណាដែលល្ងង់ខ្លៅមនុស្សណាដែលគេប្រើអោយធ្វើមិនធ្វើអញ្ចឹងទៅ អានិងគេអោយធ្វើមេណាស់គេអោយធ្វើមេដឹងនាំ!

ក៖ ចាស! លោកតាអញ្ចឹងលោកតាក្នុងសម័យប៉ុលពតនិងលោកតាចងចាំទិដ្ឋភាពអ្វីជាងគេនៅសំរាប់ជីវិតរបស់លោកតា?

ខ៖ កាលនឹងនៅក្នុងជំនាន់ប៉ុលពតគេប្រើតាអោយជីកដីជីកប្រឡាយធ្វើស្រូវប្រាំងប៉ុន្តែធ្វើស្រូវប្រាំងនិងយ៉ាប់ណាស់គ្មានជីអីវិទ្យាសាស្រ្តអីទៅដល់ទេគ្មានម៉ាស៊ីនទឹកបូមទឹកបូមអីទេអោយបាចទាំងស្នាចបាចទាំងដៃអញ្ចឹងហើយធ្វើវាគ្មានទៅកើតស្អី!

ក៖ ចាស លោកតា! ហើយ...

ខ៖ ធ្វើមិនកើតទេ ខទីមួយខទីពីរអញ្ចឹងទៅទឹកក្នុងមួយស្រែវាមួយៗក្នុងមួយហិចតាវាមានមួយរយម៉ែយបួនជ្រុង(១០០មបួនជ្រុង) ហើយអាណាទៅបាចណារីង!

កៈ អឺម!

ខៈ បាចឯណារីង(បាចទឹកនៅក្នុងស្រែ)!

កៈ ចាសលោកតា! ពិបាកណាស់អញ្ចឹងកាលនិងណោះលោកតា!

ខៈ អូ! ពិបាកណាស់ចៅស្រីមិនមែនស្រណុកទេ!

កៈ ចុះកាលជំនាន់លន់ នលវិញលោកតាបានជួបប្រទះនឹងអ្វីខ្លះដែរ?

ខៈ បើកាលសម័យលន់ នល មកដល់សម័យលន់ នល និងជួបប្រទះគេទំលាក់គ្រាប់បែក!

កៈ ចាសលោតា!

ខៈ ពីព្រោះ...

កៈ កាលនិងលោកតាគេ អោយលោកតាធ្វើអីគេដែលលោកតាក្នុងសម័យនិងលោកតា?

ខៈ តាគ្មានធ្វើអ្វីទេតាកាលនិងគ្រាន់តែជាប្រជាជនសាមញ្ញធម្មតានិងប៉ុន្តែគេទំលាក់គ្រាប់បែក!

កៈ អឹម...ឪពុកម្តាយរបស់លោកតាគាត់មានមុខរបរធ្វើអ្វីដែរ?

ខៈ គាត់នៅតែធ្វើស្រែធ្វើចំការនិងឯង!

កៈ ចាស!

ខៈ គ្មានធ្វើអីទេ!

កៈ អញ្ចឹងហ៎លោកតា
ហើយអឺ...បន្ទាប់មកលោកតាដូចជាពេលដែលលោកតាបានរួចផុតពីជំនាន់ប៉ុលពតដែលលោកតាពិបាកវេទនាកំសត់នឹងមកតើលោកតាបានប្រកបមុខរបរអីគេដែលលោកតា?

ខៈ
និងបែកមកវិញនិងកាលនោះនិយាយពីរដ្ឋាភិបាលយើងនិងគាត់ចែកបន្ទាន់ដីធ្លីនិងអោយធ្វើជាឯកជនធ្វើស្រែធ្វើភ្លឺធ្វើចំការអីនិងមានហូបមានចុកហើយចាប់ផ្តើមមានការហូបចុកអីគ្រប់គ្រាន់នាយអាយអីនិងណាស់
ខ្លះវាបានហូចចុកគ្រាន់ខ្លះក៏មិនបានហូបចុកគ្រាន់ខ្លះក៏មានការខ្វះខាតអញ្ចឹងទៅខ្លះបានចែក

ដីចែកផ្លីបានក្រុមគ្រួសារនិងវាមានក៏ប៉ុន្តែដីអីនិងមិនបានដឹកន្លែងណាមានច្រើនមានប្រជាជនតិចគឺបានច្រើនបើកន្លែងណាមានប្រជាជនច្រើនមានដីតិចបានតិចវាអញ្ចេះ!

ក៖ ចាស! ចាស!

ខ៖ ហើយមនុស្សចេះតែកើតកូនមកថែមចំណែកដីវាមានចេះកើតកូនមកអី!

ក៖ ចាស!

ខ៖ ដូចថាចៅស្រីបានដីនឹងដប់អា ឧទាហរណ៍អញ្ចឹងទៅណាស់ដូចថាសាមសិបអាអញ្ចឹង!

ក៖ ចាសលោកតា!

ខ៖
ហើយដល់ពេលចៅស្រីនៅមានកូនមានប៉ុន្មាននាក់ទៀតដូចជាមានកូនបីនាក់បួននាក់ទៀតអញ្ចេះចែកអោយវាវាមានប៉ុន្មានអាទៀតអញ្ចឹងវាអស់ហើយ!

ក៖ អូ..អញ្ចឹងៗកូនចៅលោកតាបានដីអស់ហើយណ៎!

ខ៖ វាបានៗអញ្ចឹងទៅហើយឯងនិងក៏ចែកពួកវាអស់អញ្ចឹងទៅ!

ក៖ អ៎..(សើច)!

ខ៖
ដូចខ្ញុំអញ្ចឹងខ្ញុំបានហុកសិបអាដល់ខ្ញុំរៀបការអស់កូនមួយអញ្ចឹងខ្ញុំចែកម្នាក់ម្ភៃអាៗអញ្ចឹងទៅក៏វាអស់ (សើច)!

ក៖ ចាស! ចាស! ចុះលោកតា សំរាប់ជីវិតរបស់លោកតាដែល
កាលពីតូចមកលោកតាមានធ្លាប់បានស្រមៃថាពេលធំឡើងលោកតាចង់ធ្វើអ្វីដែលទេលោកតា?

ខ៖ អូ! ចៅស្រី!
ហើយអានេះថាបើយើងនិយាយទៅតាមវាសនារបស់តាវិញចង់ធ្វើការនិងវាចង់ណាស់ហើយចង់ធ្វើការងារចង់ធ្វើអីនិងគេនិងឯងដែរ
អោយវាមានមុខមានមាត់អីអស់និងនៅក្នុងសង្គមធំតូចដែរប៉ុន្តែធ្វើមិចបើវាមិនបានរៀនសូត្របានច្រើនផងនិង!

ក៖ ចុះលោកតាចង់ធ្វើការងារខាងអ្វីដែរលោកតា?

ខ៖ ឧទាហរណ៍ដូចថាចង់ធ្វើការងារអីមួយនិងគេដែលខ្ញុំចង់ធ្វើការជាគ្រូបង្រៀនពីព្រោះថាហើយយើងចង់ធ្វើជាអ្នកអាជីវកម្មខាងដើររកស៊ីលក់ដូរអីអញ្ចឹងទៅណាស់ចេះតែចង់ហើយក៏ប៉ុន្តែយើងនិងវាអត់មានដើមទុនគ្រប់គ្រាន់អីនិងណាស់!

ក៖ ចាស! ហើយចុះកាលនិងលោកតាបានរៀនត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ បាទ?

ក៖ កាលនិងលោកតាបានរៀនត្រឹមថ្នាក់ទីប៉ុន្មានបានលោកតាឈប់រៀន?

ខ៖ តាបើនិយាយពីរឿងរៀននិងវិញតាបានរៀនត្រឹមថ្នាក់ទាបដែលនិងមិនបានរៀនខ្ពស់ទេប៉ុន្តែតាបានការសិក្សារពីការបួសរៀនទៅមុខបានច្រើនដែរ!

ក៖ លោកតាធ្លាប់បួសជាសង្ឃ?

ខ៖ ហើយដល់អញ្ចឹងទៅតាក៏មានការសិក្សារស្វែងយល់បានខ្លះៗអញ្ចឹងទៅណាស់!

ក៖ ចុះលោកតាម៉េចបានជាលោកតាសឹកមកវិញអញ្ចឹង?

ខ៖ តាសឹកមកវិញសឹកកាលពីទស្សវត្តន៍ឆ្នាំចិតសិប (ឆ្នាំ៧០) ប៉ុលពតៗវាអោយសឹកនោះ!

ក៖ ឆ្នាំចិតសិបប្រាំ (ឆ្នាំ១៩៧៥) ហើយលោកតា ឆ្នាំចិតសិបប្រាំ (ឆ្នាំ១៩៧៥) បានចូលប៉ុលពត!

ខ៖ អើ...(សើច)!

ក៖ ចុះលោកតាពេលដែល ពេលដែលលោកតាសឹកហើយនិងពេលដែលដាច់ពីប៉ុលពតមកនិងលោកតាមានថាចង់បួសទៅជាលោកសង្ឃវិញដែរទេលោកតា?

ខ៖ តាថារកអោយបួសអោយអីដែរក៏ប៉ុន្តែតាបានរៀបការយកគ្រួសារហើយ!

ក៖ លោកតារៀបការយកគ្រួសារវិញ!

ខ៖
បើបួសជាសង្ឃក៏បានដែរតែសព្វថ្ងៃនិងនោះក៏ប៉ុន្តែទាស់ត្រង់ថាមិនបួសទេនិងមិនដឹងមូលហេតុអ្វីបានជាបួស?
បួសនិងតតែមានសក្ខាបទដប់ទាន់កម្មបទដប់វាចនាកម្មបទដប់ទាល់តែយើងអនុវត្តន៍ផែនការនិងអោយបានច្បាស់លាស់ទៅតាមច្បាប់តាមវិន័យរបស់ព្រះសាមាសាមពុទ្ធនិងបានបួសបានបានបួសទៅវាមានផ្លែមានផ្កានិងបានមៈបានផល
ហើយប្រសិនបើយើងបួសហើយយើងអត់ចេះអត់ដឹង
អត់រៀនអត់សូត្រអត់ពិចារណាវិញនៅជាឧបាសកវិញប្រើសើរជាង!

ក៖ អញ្ចឹងហ៍លោកតា?

ខ៖ បាទ!

ក៖ ចុះអឺ...

ខ៖ មិនមែនថាចង់បួសជាសង្ឃនឹងចេះតែបួសនិងផ្តេសផ្តាស់ឯណា!

ក៖ និងហើយលោកតា!

ខ៖ ចេះតែយកច្បាប់វិន័យមកមកផ្ទៀតផ្ទាត់មើលណាស់!

ក៖ អញ្ចឹងលោកតាអត់បួសទៀតទេពីព្រោះលោកតាខ្លាចខុសច្បាប់ខុសវិន័យហ៎លោកតា?

ខ៖ ថាអញ្ចឹងក៏ថាបានហើយម៉្យាងវិញទៀតតានិងឃើញថាតាចាស់ហើយបួសធ្វើអីទៀត!

ក៖ ចាសលោកតា!

ខ៖ ខ្វះអីអ្នកអោយបួសក៏ប៉ុន្តែតាថា អាញមិនបួសទេ!

ក៖ ចាស!
លោកតាចុះនៅក្នុងជីវិតរបស់លោកតាមានរឿងដែលធ្វើអោយលោកតាចងចាំបំផុតហើយបំភ្លេចមិនបានលោកតារឿងដែលអាក្រក់ៗដែលធ្វើអោយជីវិតរបស់លោកតាជួបការលំបាក់ណាស់មានអីគេខ្លះ?

ខ៖
តារាល់ថ្ងៃបើនិយាយអោយអស់ទៅមានតែគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃនិងហើយនៅក្នុងជីវិ

តផ្ទាល់របស់តានិងអ្នកណាថាមិចក៏ដោយអ្នកណាថាយ៉ាងម៉េចថាទៅប៉ុន្តែអារឿងធម៌អាវ្យច្បាប់វិន័យអីនិងគឺថាតាប្រកាន់ជាប់រហូតហើយ!

ក៖ អឹម...

ខ៖ ទោះបីជាថាតាតាំងពីដើមមកនិងគេថាអោយថាអីក៏តាមិនតបដែរ
តាសុខចិត្តដើរចេញខាំមាត់សង្កត់ចិត្ត
ដូចថាមិនខឹងមិនសម្បារអីនិងទេហើយតាដើររកដើរសុំចៅស្រីអីនិងមួយរយរៀលអោយក៏អរគុណបើមិនអោយក៏មិនខឹងដែរ!

ក៖ ចាស! នៅក្នុងមួយថ្ងៃលោកតាអាចរកប្រាក់បានប៉ុន្មានដែរ?

ខ៖
មិនទៀតទេចៅស្រីជូនកាលរកបានជូនកាលរកពីរបីបួនប្រាំថ្ងៃនិងទំរាំបានបច្ច័យតិចតួចគ្រន់ចិញ្ចឹមជីវិតនិងទៅធ្វើបុណ្យធ្វើទាននាយអាយទៅផ្ទះវិញទៅអ្នកណាទៅរកធ្វើមានធ្វើអីដូចថាយើងមានអាយុចិតសិបឆ្នាំជាងហើយ!

ក៖ ចុះលោកតាអត់មានគំរោងរកការងារអ្វីផ្សេងក្រៅពីការងារដើរសុំគេនិងទេហ៎លោកតា?

ខ៖ មិនដឹងធ្វើអីទេធ្វើអីធ្វើការជាអ្នកសំណង់ធ្វើអីនិងតាធ្វើមិនរួចទេ!

ខ៖ ចុះស្រែចំការរបស់លោកតាដីធ្លីអីនៅនិងស្រុកស្រែអីនោះ?

ខ៖ សុខភាពវាមិនធានាទេថ្ងៃនិងអីអញ្ចឹងទៅវាមិនកើតអី!

ក៖ អញ្ចឹងលោកតាមកនៅនេះមកជាមួយគេដែរគេអ្នកមកជាមួយលោកតាមកដើរសុំគេនិង!

ខ៖ តាមកតែម្នាក់ឯងទេ!

ក៖ អ៎!

ខ៖ មកតែឯងនិងដល់ចាស់សុខភាពវាមិនសូវធានាទេ!

ក៖ ចុះលោកតា ជីវិតរបស់លោកតាពីមុនមកដល់ឥឡូវនិង
លោកតាធ្លាប់មានបទពិសោធន៍ល្អៗដែលRទេដែលធ្វើអោយលោកតាសប្បាយចិត្ត?

ខ៖
បើនិយាយពីរឿងបទពិសោធន៍របស់តាមិនដែលមានប្រវត្តិណាដែលដើរទៅប្លន់ដើរទៅលួចដើ

ទៅឆក់គេមិនដែលមានទេ តាតាំងពីតូចមកតាតាមដំបូលន្មានម្ដាយឪពុក បើឪពុកម្ដាយអោយទៅណាហាមមិនអោយទៅណាតាមិនទៅទេ!

កៈ ចាស! ត្រូវហើយលោកតា!

ខៈ រហូតតតែដល់បច្ចុប្បន្នសព្វថ្ងៃនិងច្បាប់រដ្ឋ...

កៈ
ចុះលោកតាមានរឿងអីសព្វថ្ងៃនិងដែលធ្វើអោយលោកតាសប្បាយដែលលោកតាធ្វើហើយនិកឃើញមកសប្បាយចិត្តលោកតាមានអត់?

ខៈ មានថៅរឿងសប្បាយៗគ្រង់ថាអ្វីៗទាំងអស់តាធ្វើទៅត្រូវ ដូចថាតាមកអញ្ចឹងមកតា

មករកអញ្ចឹងតារកសុំបើលោកអោយក៏យកទៅបើលោកមិនអោយក៏ហីទៅ!

កៈ ចាស! អញ្ចឹង...

ខៈ បើអត់មានទេក៏ហីទៅ!

កៈ ចាស! អញ្ចឹងបើគេអោយលោកតាសប្បាយចិត្តអញ្ចឹងទៅនោះ!

ខៈ អើ!
បើគេអោយក៏សប្បាយចិត្តអោយពរអោយជ័យគេអញ្ចឹងទៅអោយគេរកស៊ីមានបានអញ្ចឹងទៅគេអោយលុយកាក់និងយើងមិនដែរយកទៅផឹកស្រាស្រែកអាឡេអាឡូផ្ដេសផ្ដាសទេដូចថាពេលណាមានកម្មវិធីកសាងវត្តអារាមអញ្ចឹងទៅយើងចូលអញ្ចឹងទៅចូលជាបច្ច័យចូលជាអីអញ្ចឹងទៅ!

កៈ ចាសតា!

ខៈ ធ្វើបុណ្យធ្វើទានអីនិងទៅឧទ្ទិស មៈផល អោយដល់អ្នកជាម្ចាស់សទ្ធាអញ្ចឹងទៅណាស់!

កៈ ចាស!

ខៈ ហើយសូមអោយបានសេចក្ដីសុខសេចក្ដីចំរើនទាំងអស់គ្នាតែប៉ុននឹង!

កៈ ចាស!
លោកតាចុះលោកតាមានពាក្យអ្វីជាចុងក្រោយទៀតដើម្បីនិយាយផ្ដែផ្ដាំទៅដល់អ្នកស្ដាប់ជាពិសេសដល់កូនថៅរបស់លោកតាដែលបានស្ដាប់សំលេងរបស់លោកតា!

ខ៖
តាក្នុងជីវិតរបស់តាគ្រាន់តែថាមុននិងតាដាក់អាយុសង្ខារទៅគ្រាន់តែផ្ដែផ្ដាំទាំងអស់សូមអោយថែរក្សារនូវប្រពៃណីពីបុរាណកាលមកហើយ ខទីមួយ
ខទីពីរនិងណាស់គោរពព្រះពុទ្ធសាសនា
ខទីបីគោរពច្បាប់រដ្ឋអឺម...កុំទំនាស់នៅក្នុងច្បាប់រដ្ឋកុំទំនាស់នៅក្នុងព្រះពុទ្ធសាសនាពីព្រោះយើងជាអ្នកកាន់ព្រះពុទ្ធសាសនាប្រឹងធ្វើបុណ្យធ្វើទានមានតែប៉ុននឹង!

ក៖
ហេតុអីបានជាលោកតាចង់អោយកូនចៅជំនាន់ក្រោយកាន់ភ្ជាប់នូវព្រះពុទ្ធសាសនាលោកតា?

ខ៖
ព្រោះពុទ្ធសាសនាបានន័យថាជាសាសនាដ៏ល្អសាសនាដ៏សមរម្យណាស់មិនមានការអោយការហែកហួរគ្នាទេមិនមានការកាប់សម្លាប់គ្នាទេមិនមានការលួចប្លន់ឆក់កណ្ដៀតគ្នាទេមនុស្សដែលវាមានការលោភលន់និងដូចថាវាមិនគោរពទៅតាមព្រះពុទ្ធសាសនាប្រសិនណាបើគោរពទៅតាមព្រះពុទ្ធសាសនាគ្មានទេអត់មានទេអត់មានការលោភលន់និងបៀតបៀនទេ
លោភលន់វាអញ្ចឹងវាមិនចង់បានទេ
ពីព្រោះព្រះពុទ្ធលោកសំដែងថាចង់បានដែរក៏ប៉ុន្តែយើងរកស៊ីទៅតាម
សមាជីវៈបានប៉ុណ្ណាយើងយកប៉ុណ្ណឹងទៅ
ប៉ុន្តែមនុស្សវាមិនគិតអញ្ចឹងឯណាអ្នកខ្លះនឹងដើរលួចដើរឆក់អីគេទៅណាស់ (សើច) !

ក៖ ចាស!

ខ៖ អានេះមិនមែនជាច្បាប់ព្រះពុទ្ធទេណាស់ ព្រះពុទ្ធលោកហាមណាស់!

ក៖ ចាស!

ខ៖ អត់អោយមានធ្វើអញ្ចឹងៗទេ ក៏ប៉ុន្តែបុគ្គលវាអញ្ចឹង!

ក៖ អឺម...ចាសលោកតា
អញ្ចឹងអរគុណលោកតាច្រើនដែរលោកតាមានពាក្យអ្វីចង់និយាយបន្ថែមជាចុងក្រោយ!

ខ៖ ពាក្យចុងក្រោយតាគ្រាន់តែថាសូមផ្ដែផ្ដាំអញ្ចឹងទៅ
ក្មេងៗជំនាន់ក្រោយសូមអោយរក្សានៅច្បាប់ទំលាប់ណាស់រក្សារនៅប្រពៃណីរក្សារនៅព្រះពុទ្ធសាសនាចេះគោរពមាតាបិតាចេះដឹងគុណគ្រូចេះគោរពបងចេះគោរពប្អូន

អធ្យាស្រ័យញាតិសណ្ដានមីងអោយច្បាស់ជាមីងពូអោយច្បាស់ជាពូបងអោយច្បាស់ជាបងប្អូនអោយច្បាស់ជាប្អូនម្ដាយអោយច្បាស់ជាម្ដាយឪពុកអោយប្បាស់ជាឪពុកអញ្ចឹងទៅណាស់!

ក៖ ចាស!

ខ៖

គ្មានអីទេនាងមានតែប៉ុណ្ណឹងគ្រាន់តែថាចង់ធ្វើអនុវត្តន៍ឬមិនអនិវត្តន៍គឺស្រេចតែលើរូបគេទេ!

ក៖ ចាស! ចាស! អញ្ចឹងអរគុណច្រើនលោកតាសំរាប់ថ្ងៃនេះ!

ខ៖ បាទ!